# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

...............

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៧២៥ / ១៦.៨.២០១១
សាលដីកា
១៨ ក្រ.III.ស / ២២.១០.២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ ដោយមានសមាសភាពដូចតទៅ:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៧២៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១ រវាង៖

១- ជនជាប់ចោទឈ្មោះ [redacted] ចិន្តា ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរជាងម៉ាញ៉េ ទីកន្លែងកំណើត និងទីលំនៅមុនពេលចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០៤នាក់ ទោសពីមុនគ្មាន, ចាប់ខ្លួនថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ឃុំខ្លួនថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

២- ជនជាប់ចោទឈ្មោះ [redacted] ម៉ុន ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីកន្លែងកំណើត និងទីលំនៅមុនពេលចាប់ខ្លួន [redacted] ឪពុក ឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (រ) មានកូន០៣នាក់ ទោសពីមុនគ្មាន, ចាប់ខ្លួនថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៩ ឃុំខ្លួនថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

៣- ជនជាប់ចោទឈ្មោះ [redacted] អឿន ហៅ [redacted] សំអឿន ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ ៖

មុខរបរកសិករ ទីកន្លែងកំណើត និងទីលំនៅមុនពេលចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (រ) មានកូន ០២នាក់ ទោសពីមុនគ្មាន, ឃុំខ្លួនថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ ឃុំខ្លួនថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

មានលោក [redacted] ម៉ាច ជាមេធាវីការពារជនជាប់ចោទទាំងបីនាក់។

ជាប់ចោទពីបទៈ ប្លន់ និងសមគំនិតក្នុងអំពើប្លន់ ប្រព្រឹត្តនៅ ភូមិកោះរះលើ ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោស តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ជនរងគ្រោះឈ្មោះ [redacted] ចន្ថា អាយុ៤៩ឆ្នាំ និងប្តីឈ្មោះ [redacted] សុផាត អាយុ៥៤ឆ្នាំ ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្ន [redacted]។

## ឯដំណើររឿងមានដូចតទៅ៖

កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង៧ និង៣០នាទីយប់ មានឈ្មោះ [redacted] ចិន្តា, [redacted] ម៉ុន, [redacted] អឿន ហៅ [redacted] អឿន, [redacted] ភឿន, [redacted] ឡាឌី និងបក្សពួកមួយចំនួនទៀតមិនស្គាល់ បានជិះទូកទៅធ្វើសកម្មភាពប្លន់ នៅផ្ទះរបស់ឈ្មោះ [redacted] សុផាត និងប្រពន្ធឈ្មោះ [redacted] ចន្ថា ស្ថិតនៅ ភូមិកោះរះលើ ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល ដោយប្លន់បានមាស ៦តំឡឹង ប្រាក់ដុល្លាចំនួន ១.៥០០ដុល្លារអាមេរិក និងលុយខ្មែរចំនួន១៦.០០០.០០០រៀល និងទូរស័ព្ទដៃចំនួន០២គ្រឿង។ ដោយ ពេលឈ្មោះ [redacted] អឿន ជាអ្នកយកទូករបស់ខ្លួនចម្លងទៅ។ ក្រោយពេលប្លន់បានឈ្មោះ [redacted] ចិន្តា, [redacted] ម៉ុន, [redacted] អឿន, [redacted] ភឿន, [redacted] ឡាឌី រួមជាមួយបក្សពួក បានលួចទូកអ្នកស្រុកឆ្លងមក កាន់ត្រើយម្ខាង នៅកៀនស្វាយ ដែលបក្សពួកវាមួយចំនួនទៀតជិះឡានមកចាំទទួលយកទៅភ្នំពេញតែម្តង, ដោយពេល នោះ ពួកវាបានទៅជួលផ្ទះសំណាក់នៅម្តុំចោមចៅដើម្បីចែកលុយគ្នា។ ចំណែក ជនរងគ្រោះឈ្មោះ [redacted] សុផាត ក៏បានត្រូវរងរបួសក្បាលជាទម្ងន់ដោយសារឈ្មោះ [redacted] ចិន្តា ហៅ ជិន វាយនិងញញួរបណ្តាល ឲ្យបែកក្បាល និងបញ្ជូនទៅកាន់មន្ទីរពេទ្យកាល់ម៉ែតភ្លាមៗដើម្បីព្យាបាលដែរ ហើយឈ្មោះ [redacted] ចិន្តា ជាប្រពន្ធ ក៏បានប្តឹងទៅសមត្ថកិច្ច ហើយក៏បានចាប់ជនល្មើសបានជាបន្តបន្ទាប់ រួចចាត់បញ្ជូនមកឃុំ ខ្លួនរហូតដល់សព្វថ្ងៃនេះ។ ចំណែកឈ្មោះ [redacted] ភឿន, [redacted] ឡាឌី និងបក្សពួកមួយចំនួនទៀតមិនស្គាល់ ក៏បានគេចខ្លួនក្រោយពេលប្រព្រឹត្តបទល្មើស តែចៅក្រមស៊ើប សួរបានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនរួច ហើយដែរ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៥ «ស» ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ របស់ សាលាដំបូងខេត្តកណ្តាល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១. ផ្តន្ទាទោសលើជនជាប់ចោទ:

ក- ឈ្មោះ [redacted] ចិន្តា ភេទប្រុស អាយុ៣៣ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន០៩ឆ្នាំ គិតពីថ្ងៃ ឃុំខ្លួន ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩។

ខ- ឈ្មោះ [redacted] ម៉ុន ភេទប្រុស អាយុ៤២ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន០៩ឆ្នាំ គិតពីថ្ងៃ ឃុំខ្លួន ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

គ- ឈ្មោះ [redacted] ភឿន ភេទប្រុស អាយុ៤២ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន០៩ឆ្នាំ គិតពីថ្ងៃ ចាប់ខ្លួនបាន។

ឃ- ឈ្មោះ [redacted] ឡាឌី ភេទប្រុស អាយុ៣៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន០៩ឆ្នាំ គិតពីថ្ងៃ ចាប់ខ្លួនបាន។

ង- ឈ្មោះ [redacted] អឿន ភេទប្រុស អាយុ៣២ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន០៩ឆ្នាំ គិតពីថ្ងៃ ឃុំខ្លួន ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩។ ពីបទ ប្លន់ ប្រព្រឹត្តនៅ ភូមិកោះរះលើ ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩។ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២. បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] ចិន្តា, សឿង [redacted], [redacted] អឿន, [redacted] ភឿន, និងឈ្មោះ [redacted] ឡាឌី រួមគ្នាសងប្រាក់ដែលបាត់បង់សរុបមាន មាស៦តំឡឹង (មាសតីឡូ) ប្រាក់ដុល្លាចំនួន ១.៥០០ដុល្លាអាមេរិក និងប្រាក់រៀលចំនួន១៦លានរៀល និងសំណងជម្ងឺចិត្តចំនួន ២០.០០០.០០០៛ (ម្ភៃលានរៀល) ទៅឲ្យជនរងគ្រោះឈ្មោះ [redacted] ចន្ថា នៅពេលសាលក្រមស្ថាពរ។ សំណូមពរលើសពីនេះបដិសេធចោល។

- ករណីឈ្មោះ [redacted] ចិន្តា, [redacted] ម៉ុន, [redacted] អឿន, [redacted] ភឿន, និងឈ្មោះ [redacted] ឡាឌី ពុំមានប្រាក់សងគ្រប់ចំនួនតាមការបង្គាប់ខាងលើទេ សម្រេចដាក់គុកបង្ខំលើរូបរាងកាយតាមមាត្រា ៥២៣ និងមាត្រា ៥៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣. វត្ថុតាងរួមមាន: ញញួរដងឈើប្រវែង ៣៥សម ០១, ស្បែកជើងពណ៌ខ្មៅ ម៉ាកDADA ចំនួន០១គូ, កាំបិតបន្លែដងជ័រពណ៌លឿងចំនួន០១, ពិលជ័រពីរណាត់ពណ៌ក្រហមចំនួន០១, ខ្សែ ពណ៌លឿង ប្រវែង១,៣០ម ចំនួន០១ខ្សែ, ឈើស្លាបព្រិលចំនួន០៤បន្ទះ, ប្រអប់ដែកចំនួន០១ និង ចានជ័រចំនួន០១ ត្រូវរឹបអូសកំទេចចោល។

៤. សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ វេលាម៉ោង១០ និង៣០នាទីព្រឹក ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចិន្តា, [redacted] ម៉ុន និងឈ្មោះ [redacted] អឿន, មេធាវីជនជាប់ចោទ និងជនរងគ្រោះឈ្មោះ [redacted] ចិន្តា, [redacted] សុជាត និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ភឿន និងឈ្មោះ [redacted] ឡាឌី។

ទុក្ខសិទ្ធិប្ដឹងតវ៉ាតាមកំណត់ច្បាប់។

បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ របស់ជនជាប់ចោទ ឈ្មោះ [redacted] អឿន ជា សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៥«ស» ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ចិន្តា ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៥ «ស» ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

បានឃើញបណ្ដឹងឧទ្ធរណ៍ បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ម៉ុន ជាជនជាប់ចោទ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៥ «ស» ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ជនជាប់ចោទឈ្មោះ [redacted] អឿន, ឈ្មោះ [redacted] ចិន្តា និងឈ្មោះ [redacted] ម៉ុន ឆ្លើយថា ពួកខ្លួនពិតជាបានរួមគ្នា ធ្វើសកម្មភាពប្លន់ផ្ទះជនរងគ្រោះឈ្មោះ [redacted] សុជាត និងនាង [redacted] ចន្ថា មែន កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងសកម្មភាពនេះ ពួកខ្លួនប្រមូលយកបានមាស ៦តម្លឹង, ប្រាក់ដុល្លាចំនួន ១.៥០០$ (មួយពាន់ប្រាំរយដុល្លាអាមេរិក), ប្រាក់រៀលចំនួនដប់ប្រាំមួយលានរៀល និងទូរសព្ទ័ពីរគ្រឿង ពេលនោះឈ្មោះ [redacted] ចិន្តា បានយកញញួរវាយក្បាលជនរងគ្រោះមែន។ ពួកខ្លួនប្តឹងឧទ្ធរណ៍មកនេះ សុំលោកប្រធានបន្ធូរបន្ថយទោសដល់ពួកខ្លួន។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

មានអង្គហេតុដូចការចោទប្រកាន់របស់តំណាងអយ្យការអមសាលាដំបូង, ឃើញថាសាលក្រមព្រហ្មទណ្ឌលេខ ២៥ "ស" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកណ្តាល សម្រេចមានសំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវហើយ គប្បីតម្កល់សាលក្រមនេះទុកជាបានការ។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

កូនក្តីខ្លួនទាំង៣នាក់នេះ ទទួលស្គាល់ថាបានប្រព្រឹត្តដូចការចោទប្រកាន់ ហើយការសារភាព នេះគាត់ធ្វើឡើងតាំងពីដំណាក់កាល នីតិវិធីនគរបាលយុត្តិធម៌ រហូតមកទល់ពេលនេះ អញ្ចឹងមាន ន័យថាគាត់ដឹងកំហុស ហើយការប្រព្រឹត្តនេះក៏ជាលើកទី១ ហើយកូនក្តីខ្លួនមានប្រពន្ធកូនដែលត្រូវទទួលខុសត្រូវទៀត ដូចនេះកូនក្តីខ្លួនគាត់សូមសំណូមពរ លោកប្រធានក្រុមប្រឹក្សា ពិចារណា បន្ធូរបន្ថយទោស។ បើផ្អែកតាមទំនាក់ទំនងច្បាប់ឃើញថា កូនក្តីខ្លួនត្រូវបានផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលច្បាប់នេះត្រូវបាននិរាករណ៍ហើយ ដូចនេះ សូមក្រុមប្រឹក្សាពិចារណា កែប្រែមក

ច្បាប់ថ្មីតាមមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងសូមផ្តល់ស្ថានសម្រាលទោសត្រឹម៥ឆ្នាំ ដើម្បីឲ្យគាត់មានឱកាសកែប្រែខ្លួន។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] អឿន ជាជនជាប់ចោទ បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ចិន្តា ជាជនជាប់ចោទ និង បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ម៉ុន ជាជនជាប់ចោទ ធ្វើឡើង នៅក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២- កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩ វេលាម៉ោង៧ និង៣០នាទីយប់ មានជនល្មើសមួយ ក្រុម មានឈ្មោះ [redacted] ចិន្តា, ឈ្មោះ [redacted] ម៉ុន, ឈ្មោះ [redacted] អឿន, ឈ្មោះ [redacted] អឿន និងឈ្មោះ [redacted] ឡាឌី បាននាំគ្នាជិះទូក ដោយមានឈ្មោះ [redacted] អឿន ជាអ្នកយកទូកមកចម្លង បានធ្វើសកម្មភាពប្លន់ នៅផ្ទះ របស់ឈ្មោះ [redacted] ជាត និងអ្នកស្រី ទេព ចន្ថា ជាប្រពន្ធ ស្ថិតនៅ ភូមិកោះរះលើ ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល។ ក្នុងសកម្មភាពនេះ ជនល្មើសបានយកបាននូវមាស៦តម្លឹង, ប្រាក់ដុល្លា ១.៥០០$ (មួយពាន់ប្រាំរយដុល្លាអាមេរិក) និងប្រាក់រៀលមានចំនួន ដប់ប្រាំមួយលានរៀល។

៣- ចំពោះករណីនេះ ជនជាប់ចោទបានឆ្លើយសារភាពព្រមគ្នាថា ពួកខ្លួនពិតជាបានរួមគ្នាធ្វើ សកម្មភាពប្លន់ផ្ទះជនរងគ្រោះឈ្មោះ [redacted] សុជាត និងនាង [redacted] ចន្ថា មែន កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩។ ក្នុងសកម្មភាពនេះ ពួកខ្លួនប្រមូលយកបានមាស ៦តម្លឹង, ប្រាក់ដុល្លាចំនួន ១.៥០០$ (មួយពាន់ប្រាំរយដុល្លាអាមេរិក), ប្រាក់រៀលចំនួន ១៦.០០០.០០០(ដប់ប្រាំមួយលាន)រៀល និងទូរសព្ទ័ ពីរគ្រឿង ពេលនោះឈ្មោះ [redacted] ចិន្តា បានយកកញ្ចូវវាយក្បាលជនរងគ្រោះមែន។

៤- មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ពីបទ ប្លន់ ប្រព្រឹត្តនៅ ភូមិកោះរះលើ ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៩ បទល្មើសមានចែង និងផ្តន្ទាទោស តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៦- សំអាងហេតុដែលសាលាដំបូងខេត្តកណ្តាល លើកយកមកបញ្ជាក់ មានភាពច្បាស់លាស់ និង...

គ្រប់ជ្រុងជ្រោយហើយ សាលាឧទ្ធរណ៍មិនលើកយកសំអាងហេតុដដែលនោះមកបញ្ជាក់ឡើងវិញទៀតទេ

៧- សាលក្រមព្រហ្មទណ្ឌលេខ ២៥ "ស" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកណ្ដាល សម្រេចមានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១- ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] អឿន, បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ចិន្តា និងបណ្ដឹង ឧទ្ធរណ៍ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ម៉ុន ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៥ "ស" ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការពេញទាំងមូល។

៣- បង្គាប់ឲ្យបន្តឃុំខ្លួនជនជាប់ចោទ ទាំង៣នាក់ ដូចមានឈ្មោះខាងលើ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ ចំពោះមុខជាប់ចោទឈ្មោះ [redacted] ចិន្តា, ឈ្មោះ [redacted] ម៉ុន និងឈ្មោះ [redacted] អឿន និងមេធាវីការពារជនជាប់ចោទ, បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**៚

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

........................................................................................................

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ, ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៥

ក្រឡាបញ្ជី

[redacted]

២០៣